# ឧរគជាតក




ព្រះសាស្តា កាលស្តេចគង់នៅវត្តជេតពន ទ្រង់ប្រារព្ធកុដុម្ពិកៈម្នាក់ដែលមានកូនស្លាប់ បានត្រាស់ព្រះធម្មទេសនានេះ មានពាក្យថា **ឧរគោវ តចំ ជិណ្ណំ** ដូច្នេះជាដើម ។

រឿងរ៉ាវបច្ចុប្បន្ន ដូចរឿងកុដុម្ពិកៈដែលមានភរិយាស្លាប់និងមានបិតាស្លាប់នុ៎ះឯង ។ សូម្បីក្នុងជាតកនេះ ព្រះសាស្តាក៏យាងទៅកាន់និវេសន៍របស់កុដុម្ពិកៈ យ៉ាងនោះដែរ និងត្រាស់សួរគាត់ដែលមកថ្វាយបង្គំអង្គុយរួចហើយថា នែអាវុសោ អ្នកសោកសៅឬ កាលកុដុម្ពិកៈនោះក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គសោយសោក ចាប់តាំងពីបុត្ររបស់ខ្ញុំព្រះអង្គស្លាប់ទៅហើយ ទើបទ្រង់ត្រាស់ថា នែអាវុសោ ឈ្មោះថា វត្ថុដែលមានការបែកធ្លាយជាធម្មតា រមែងបែកធ្លាយទៅ, ឈ្មោះថា វត្ថុដែលមានការវិនាសទៅជាធម្មតា រមែងវិនាសទៅ, វត្ថុដែលមានការបែកធ្លាយ និងវិនាសទៅជាធម្មតានោះ មិនមែនមានក្នុងត្រកូលតែមួយប៉ុណ្ណោះទេ មិនមែនមានតែក្នុងស្រុកមួយប៉ុណ្ណោះទេ, ឈ្មោះថា ធម៌ដែលមិនស្លាប់ រមែងមិនមានក្នុងភពទាំងបី ក្នុងចក្រវាឡដែលប្រមាណមិនបាន

សូម្បីសង្ខារតែមួយដែលអាចតាំងនៅដោយភាវៈនោះ ឈ្មោះថា ទៀងទាត់ រមែងមិនមានទេ, សត្វទាំងពួងមានសេចក្ដីស្លាប់ជាធម្មតា, សង្ខារទាំងពួងមានការបែកធ្លាយទៅជាធម្មតា, សូម្បីបោរាណបណ្ឌិតទាំងឡាយ កាលបុត្រស្លាប់ហើយ គិតថា វត្ថុដែលមានការស្លាប់ជាធម្មតា រមែងស្លាប់ទៅហើយ វត្ថុដែលមានការវិនាសជាធម្មតា តែងវិនាសទៅហើយ ហើយក៏មិនសោកសៅ ដូច្នេះកាលកុដុម្ពិកៈនោះទូលសូមអង្វរហើយ ទ្រង់នាំយកអតីតនិទានមកថា ៖

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងត្រកូលព្រាហ្មណ៍ ដែលជាអ្នកស្រុកជិតទ្វារក្រុងពារាណសី លោករៀបចំទុកដាក់ទ្រព្យសម្បត្តិ ចិញ្ចឹមជីវិតដោយកសិកម្ម ។ ព្រះពោធិសត្វនោះមានកូន ២ នាក់ គឺកូនប្រុស ១ កូនស្រី ១ ។ ព្រះពោធិសត្វកាលបុត្រចម្រើនវ័យហើយ បាននាំនាងកុមារិកាមកពីត្រកូលស្មើគ្នា មកឲ្យបុត្រនោះ ព្រោះហេតុដូច្នេះ ក្នុងគ្រួសារនោះ ទើបមានមនុស្ស ៦ នាក់ មួយអន្លើដោយនាងទាសី គឺ ព្រះពោធិសត្វ ភរិយា បុត្រ ធីតា កូនប្រសាស្រី និងទាសី ។ មនុស្សទាំងនោះបានជាអ្នកព្រមព្រៀងគ្នា ត្រេកអរនឹងគ្នា រស់នៅដោយសេចក្ដីស្រឡាញ់គ្នា ។ ព្រះពោធិសត្វតែងឲ្យឱវាទដល់អ្នកទាំង ៥ ដ៏សេសយ៉ាងនេះថា អ្នកទាំងឡាយចូរឲ្យទាន ដោយនិយាមតាមទំនងដែលរកបាន ចូររក្សាសីល ចូរធ្វើឧបោសថកម្ម ចូរចម្រើនមរណស្សតិ ចូរកំណត់សេចក្ដីស្លាប់របស់អ្នកទាំងឡាយចុះ ព្រោះសេចក្ដីស្លាប់របស់សត្វទាំងនេះ ជារបស់ទៀង ជីវិតមិនទៀងទេ សង្ខារទាំងពួងមិនទៀង មានសេចក្ដីអស់ទៅ សាបសូន្យទៅជាធម្មតា អ្នកទាំងឡាយចូរជាអ្នកមិនប្រមាទទាំងពេលយប់និងពេលថ្ងៃចុះ ។ ជនទាំង ៥ នោះទទួលឱវាទថា សាធុ ហើយជាអ្នកមិនប្រមាទ នាំគ្នាចម្រើនមរណស្សតិ ។

ថ្ងៃមួយ ព្រះពោធិសត្វទៅស្រែជាមួយនឹងបុត្រ ភ្ជួរស្រែ ។ បុត្រទាញសំរាមមកដុត។ ក្នុងទីមិនឆ្ងាយពីបុត្រនោះ មានអាសិរពិសនៅក្នុងដំបូកមួយកន្លែង ។ ផ្សែងភ្លើងប៉ះភ្នែករបស់អាសិរពិសនោះ ។ ពស់នោះក្រោធហើយ លូនចេញមក ដោយគិតថា ភ័យកើតដល់យើង ព្រោះអាស្រ័យបុរសនេះ ទើបចឹកបុត្រ លិចទាំង ៤ ចង្កូម ធ្វើឲ្យដួល រួចលូនត្រឡប់ទៅវិញ ។ បុត្រនោះប្រកាច់ហើយដួលចុះ ។ ព្រះធិពោសត្វក្រឡេកមកមើលឃើញបុត្រដួលចុះ ទើបបញ្ឈប់គោ ហើយទៅ ដឹងថា បុត្រស្លាប់ហើយ ទើបលើកបុត្រ ដាក់ឲ្យដេកនៅទៀបគល់ឈើមួយកន្លែង យកសំពត់គ្រប មិនស្រែកយំ មិនបរិទេវៈឡើយ ដោយគិតថា ធម៌ដែលការបែកធ្លាយ តែងបែកធ្លាយ ធម៌ដែលមានការស្លាប់ តែងស្លាប់ សង្ខារទាំងពួងមិនទៀង នឹងសម្រេចដោយសេចក្តីស្លាប់ ដូច្នេះហើយ ក៏កំណត់ដល់ភាពមិនទៀង រួចទើបភ្ជួរស្រែបន្ត ។ ព្រះពោធិសត្វឃើញបុរសអ្នកស្និទ្ធស្នាលម្នាក់ ដើរទៅតាមផ្លូវជិតស្រែខ្លួន ទើបសួរថា នែអ្នក តើអ្នកទៅផ្ទះឬ ? កាលបុរសនោះពោលថា បាទ ទើបពោលថា បើយ៉ាងនោះ សូមលោកទៅកាន់ផ្ទះសូម្បីរបស់ខ្ញុំផង ហើយប្រាប់ចំពោះនាងព្រាហ្មណ៍ថា ថ្ងៃនេះ មិនចាំបាច់នាំភត្តាហារដើម្បីបុគ្គលពីរនាក់ ដូចកាលមុនទេ គប្បីនាំអាហារ សម្រាប់បុគ្គលតែម្នាក់ប៉ុណ្ណោះ និងកាលមុន ទាសីតែម្នាក់ប៉ុណ្ណោះ នាំអាហារមក តែថ្ងៃនេះ អ្នកទាំង ៤ គប្បីស្លៀកដណ្តប់សំពត់ស ហើយកាន់របស់ក្រអូបនិងផ្កាឈើមក ។ បុរសនោះទទួលថា ល្អ ហើយទៅប្រាប់ដល់នាងព្រាហ្មណីយ៉ាងនោះ ។ នាងព្រាហ្មណីសួរថា នែអ្នក ដំណឹងនេះអ្នកណាឲ្យអ្នកមក ? បុរសនោះឆ្លើយថា បពិត្រលោកស្រីព្រាហ្មណ៍ឲ្យមក ។ នាងព្រាហ្មណីនោះដឹងថា បុត្ររបស់យើងស្លាប់ហើយ សូម្បីសេចក្តីវិបរិតត្រឹមតែថា សេចក្តីញ័ររន្ធត់ចិត្ត ក៏មិនបានមានដល់នាងព្រាហ្មណីនោះ ។ នាងមានចិត្តអប់រំទុកល្អហើយយ៉ាងនេះ ស្លៀកដណ្តប់សំពត់ស កាន់របស់ក្រអូបនិងផ្កាឈើ ឲ្យទាសីនាំយកអាហារ ហើយបានទៅកាន់ស្រែជាមួយនឹងបុគ្គលដ៏សេស ។ សូម្បីបុគ្គលតែម្នាក់ក៏មិនបានមានការស្រែកយំ ឬការរៀបរាប់ឡើយ ។

ព្រះពោធិសត្វអង្គុយក្រោមស្រមោលម្ទប់ (ឈើ) ដែលបុត្រប្រុសដេកនុ៎ះឯង បរិភោគអាហារ ។ កាលព្រះពោធិសត្វបរិភោគរួច មនុស្សសូម្បីទាំងអស់នាំឱសមក លើកបុត្រនោះឡើងកាន់ជើងថ្ករ បូជាដោយគ្រឿងក្រអូប និងផ្កាឈើហើយដុត ។ ទឹកភ្នែកសូម្បីតែមួយដំណក់ មិនមានដល់អ្នកណាៗឡើយ ទាំងអស់គ្នាជាអ្នកចម្រើនមរណស្សតិទុកល្អហើយ ។ ដោយតេជៈនៃសីលរបស់បុគ្គលទាំងនោះ អាសនៈស្តេចសក្កៈសម្តែងអាការក្តៅ ។ ស្តេចសក្កៈនោះពិចារណាថា អ្នកណាហ្ន៎ ប្រាថ្នានឹងឲ្យយើងឃ្លាតចាកទី ទ្រង់ជ្រាបថា ភាពក្តៅព្រោះតេជៈនៃគុណរបស់ជនទាំងនោះ ជាអ្នកមានចិត្តជ្រះថ្លា ទ្រង់ត្រិះរិះថា យើងទៅកាន់សំណាក់ជនទាំងនេះ ធ្វើឲ្យគេបន្លឺសីហនាទ ក្នុងវេលាបន្លឺសីហនាទស្រេចហើយ នឹងធ្វើនិវេសន៍របស់ជនទាំងនោះ ឲ្យពេញដោយរតនៈទាំង ៧ ប្រការ រួចមកទើបគួរ ដូច្នេះស្តេចទៅក្នុងទីនោះដោយរហ័ស ហើយមកឈរនៅចំណែកទីប៉ាធា ត្រាស់ថា នៃអ្នក ពួកអ្នកធ្វើអ្វី ? ។ ជនទាំងនោះពោលថា បពិត្រអ្នកជាម្ចាស់ ពួកយើងដុតមនុស្សម្នាក់ ។ ស្តេចសក្កៈត្រាស់ថា ពួកលោកមិនមែនដុតមនុស្សទេ តែបែបនេះប្រហែលជាសម្លាប់ម្រឹគមួយហើយចម្អិន ។ ជនទាំងនោះពោលថា បពិត្រអ្នកជាម្ចាស់ មិនមែនទេ ពួកយើងដុតមនុស្ស ។ ស្តេចសក្កៈត្រាស់ថា បើយ៉ាងនោះ គេគង់នឹងជាមនុស្សដែលមានពៀរនឹងពួកលោក ។ លំដាប់នោះ ព្រះពោធិសត្វពោលនឹងស្តេចសក្កៈនោះថា បពិត្រអ្នកជាម្ចាស់ គេជាបុត្រប្រុសរបស់ពួកយើង មិនមែនអ្នកមានពៀរនឹងគ្នាទេ ។ ស្តេចសក្កៈត្រាស់ថា បើយ៉ាងនោះ គេគង់ជាបុត្រ ដែលមិនជាទីស្រឡាញ់របស់លោក ។ ព្រះពោធិសត្វពោលថា បពិត្រអ្នកជាម្ចាស់ គេជាបុត្រដែលជាទីស្រឡាញ់ក្រៃលែងរបស់ខ្ញុំ ។ ស្តេចសក្កៈត្រាស់ថា បើចឹង ព្រោះហេតុអ្វី លោកទើបមិនស្រែកយំ ? ព្រះពោធិសត្វកាលនឹងប្រាប់ហេតុដែលមិនយំ ទើបពោលគាថាទី ១ ថា

**ឧរគោវ តចំ ជិណ្ណំ, ហិត្វា គច្ឆតិ សំ តនុំ;**
**ឯវំ សរីរេ និព្ភោគេ, បេតេ កាលកតេ សតិ ។**

*កូនរបស់ខ្ញុំ លះបង់នូវសរីរៈហើយទៅ ដូចជាពស់លះបង់នូវសំណកចាស់ កាលបើសរីរៈប្រើប្រាស់មិនបាន ធ្វើកាលកិរិយា ទៅកាន់លោកខាងមុខយ៉ាងនេះ ។*

ឌយ្ហមានោ ន ជានាតិ, ញាតីនំ បរិទេវិតំ;
តស្មា ឯតំ ន សោចាមិ, គតោ សោ តស្ស យា គតិ ។

*រាងកាយកាលត្រូវគេដុត រមែងមិនដឹងនូវសេចក្ដីខ្សឹកខ្សួល នៃញាតិទាំងឡាយ ព្រោះហេតុនោះ ទើបខ្ញុំមិនសោកស្ដាយ ចំពោះកូនទុំះ គតិណាជារបស់គេ គេក៏ទៅកាន់គតិនោះ ។*

*លោកពោលអធិប្បាយថា បពិត្រអ្នកជាម្ចាស់ ធម្មតាពស់កាលសកសំណកចាស់ហើយ មិនក្រឡេកមើល មិនសម្លឹងមើល លះបង់ចោលហើយទៅយ៉ាងណា កូនរបស់ខ្ញុំលះបង់សីរីរៈរបស់ខ្លួន ហើយទៅក៏យ៉ាងនោះ កាលសរីរៈកូនរបស់ខ្ញុំនោះវៀរចាកជីវិតិន្ទ្រិយប្រើការមិនបាន យ៉ាងនេះ និងកាលកូនរបស់ខ្ញុំនោះ ទៅហើយ គឺវិលត្រឡប់ទៅហើយ ធ្វើមរណកាលហើយ ប្រយោជន៍អ្វី ដោយសេចក្ដីអាណិត ឬសេចក្ដីសោកស្ដាយ ។ សាកសពត្រូវគេយកលំពែងចាក់ហើយដុត រមែងមិនរលឹកដឹងសុខនិងទុក្ខ យ៉ាងណា កូនរបស់ខ្ញុំនេះ រមែងមិនដឹងសូម្បីសេចក្ដីសោកស្ដាយរបស់ពួកញាតិ ក៏យ៉ាងនោះ ព្រោះហេតុនោះ ខ្ញុំទើបមិនសោយសោកនឹងបុត្រ ។ គតិរបស់ខ្លួនគេយ៉ាងណា គេនឹងទៅកាន់គតិនោះ ។*

*ស្ដេចសក្កៈស្ដាប់ពាក្យរបស់ព្រះពោធិសត្វហើយ ត្រាស់សួរនាងព្រាហ្មណីថា ម្នាលនាង គេជាអ្វីនឹងនាង ? នាងព្រាហ្មណីឆ្លើយថា បពិត្រអ្នកជាម្ចាស់ គេជាបុត្រ ដែលខ្ញុំបរិហាររក្សាដោយគភ៌ អស់ ១០ ខែ ឲ្យផឹកទឹកដោះហើយទំនុកបម្រុង ចិញ្ចឹមឲ្យចម្រើន ធំធាត់ឡើង ។ ស្ដេចសក្កៈត្រាស់ថា ម្នាលនាង បិតាមិនយំព្រោះជាបុរស ក៏លើកទុកសិនចុះ*

ហឫទ័យមាតាទន់ ព្រោះហេតុអ្វី នាងមើលមិនយំ ។ នាងព្រាហ្មណីនោះ កាលនឹងប្រាប់ហេតុដែលមិនយំ ទើបពោលគាថា ២ គាថាថា ៖

អនព្ភិតោ តតោ អាគា, អននុញ្ញាតោ ឥតោ គតោ;
យថាគតោ តថា គតោ, តត្ថ កា បរិទេវនា ។

កូន (របស់ខ្ញុំ) ដែលមកអំពីបរលោក ខ្ញុំក៏មិនបានអង្វរ គេទៅអំពីលោកនេះ ក៏ខ្ញុំមិនអនុញ្ញាត គេមកយ៉ាងណា គេក៏ទៅយ៉ាងនោះ ខ្សឹកខ្សួលធ្វើអ្វី ព្រោះការដែលគេទៅនោះ ។

ឌយ្ហមានោ ន ជានាតិ, ញាតីនំ បរិទេវិតំ;
តស្មា ឯតំ ន សោចាមិ, គតោ សោ តស្ស យា គតិ ។

រាងកាយកាលត្រូវគេដុត រមែងមិនដឹងនូវសេចក្ដីខ្សឹកខ្សួល នៃញាតិទាំងឡាយទេ ព្រោះហេតុនោះ ទើបខ្ញុំមិនសោកនឹងកូននុ៎ះ គតិណាជារបស់គេ គេក៏ទៅកាន់គតិនោះ ។

ស្ដេចសក្កៈស្ដាប់ពាក្យរបស់នាងព្រាហ្មណីហើយ ទើបសួរប្អូនស្រីរបស់អ្នកស្លាប់ថា នែនាង គេជាអ្វីនឹងនាង ? ប្អូនស្រីពោលថា បពិត្រអ្នកជាម្ចាស់ គាត់ជាបងប្រុសរបស់ខ្ញុំ ។ ស្ដេចសក្កៈត្រាស់ថា នែនាង ធម្មតាប្អូនស្រីទាំងឡាយ រមែងមានសេចក្ដីស្រឡាញ់បងប្រុស ព្រោះហេតុអ្វី ទើបនាងមិនស្រែកយំ ? ចំណែកប្អូនស្រីនោះ កាលនឹងប្រាប់ហេតុដែលមិនស្រែកយំ ទើបពោលគាថា ២ គាថាថា ៖

សចេ រោទេ កិសា អស្សំ, តស្សា មេ កឹ ផលំ សិយា;
ញាតិមិត្តសុហជ្ជានំ, ភិយ្យោ នោ អរតី សិយា ។

បើខ្ញុំយំទួញ ខ្ញុំនឹងស្គាំងស្គម កាលខ្ញុំនោះយំទួញ នឹងមានផលដូចម្ដេច សេចក្ដីមិនត្រេកអររបស់ពួកញាតិមិត្ត និងសម្លាញ់របស់យើង គប្បីមានដោយក្រៃលែង ។

ឌយ្ហមានោ ន ជានាតិ, ញាតីនំ បរិទេវិតំ;

តស្មា ឯតំ ន សោចាមិ, គតោ សោ តស្ស យា គតិ ។

រាងកាយកាលត្រូវគេដុត រមែងមិនដឹងនូវសេចក្ដីខ្សឹកខ្សួល នៃញាតិទាំងឡាយទេ ព្រោះហេតុនោះ ទើបខ្ញុំមិនសោកនឹងបងនោះ គតិណាជារបស់គេគេក៏ទៅកាន់គតិនោះ ។

សក្កទេវរាជស្ដាប់ពាក្យប្អូនស្រីហើយ ទើបសួរភរិយារបស់បុត្រដែលស្លាប់នោះថា នែនាង គេជាអ្វីនឹងនាង ? ភរិយាឆ្លើយថា បពិត្រអ្នកជាម្ចាស់ គាត់ជាប្ដីរបស់ខ្ញុំ ។ ស្ដេចសក្កៈត្រាស់ថា ធម្មតាស្ត្រីទាំងឡាយ កាលប្ដីស្លាប់ទៅរមែងជាស្រីមេម៉ាយ ឥតមានទីពឹង ព្រោះហេតុអ្វី ទើបនាងមិនស្រែកយំ ? ភរិយារបស់បុត្រនោះ កាលប្រាប់ហេតុនៃការស្រែកយំដល់ស្ដេចសក្កៈនោះ ទើបពោលគាថា ២ គាថាថា

យថាបិ ទារកោ ចន្ទំ, គច្ឆន្តមនុរោទតិ;
ឯវំសម្បទមេវេតំ, យោ បេតមនុសោចតិ ។

ទារកយំទារព្រះចន្ទ្រ ដែលកំពុងចរទៅ យ៉ាងណា បុគ្គលដែលសោករកអ្នកស្លាប់ទៅកាន់លោកខាងមុន នេះឯង ជាគ្រឿងប្រៀបធៀប យ៉ាងនោះដែរ ។

ឧយ្ហមានោ ន ជានាតិ, ញាតីនំ បរិទេវិតំ;
តស្មា ឯតំ ន សោចាមិ, គតោ សោ តស្ស យា គតិ ។

រាងកាយកាលត្រូវគេដុតរមែងមិនដឹងនូវសេចក្ដីខ្សឹកខ្សួល នៃពួកញាតិទេ ព្រោះហេតុនោះ ទើបខ្ញុំមិនសោកនឹងប្ដីនុ៎ះ គតិណាជារបស់គាត់ គាត់ក៏ទៅកាន់គតិនោះ ។

គាថានោះមានសេចក្ដីថា ទារកតូចមិនដឹងវត្ថុដែលគួរនិងមិនគួរ វត្ថុដែលគួរបាន នឹងមិនគួរបាន ក្នុងទីណាទីណា អង្គុយនៅលើភ្លៅរបស់មាតា ឃើញព្រះចន្ទ្រពេញវង់ក្នុងខែជាថ្ងៃពេញបូណ៌មី ត្រាច់ទៅក្នុងអាកាស រមែងស្រែកយំថា ម៉ែ ចូរឲ្យព្រះចន្ទ្រដល់ខ្ញុំ ម៉ែ ចូរឲ្យព្រះចន្ទ្រដល់ខ្ញុំ ដូច្នេះយ៉ាងណា សេចក្ដីដល់ព្រមឧបមេយ្យក៏ដូច្នេះដែរ គឺការស្រែក

យំរបស់អ្នកសោកស្តាយដល់អ្នកដែលលះបង់ទៅ គឺស្លាប់ទៅហើយនោះ សម្រេចសេចក្តីឧបមេយ្យដូច្នោះដែរ ទាំងជាការឆោតល្ងង់ក្រៃលែងជាងពាលទារក (ដែលស្រែកយំចង់បានព្រះចន្ទ្រនោះទៀត) ព្រោះហេតុអ្វី ? ព្រោះទារកតូចនោះស្រែកយំទារព្រះចន្ទ្រ ដែលមាន ចំណែកស្វាមីរបស់ខ្ញុំស្លាប់ហើយ ឥឡូវនេះ មិនប្រាកដទេ សូម្បីគេយកលំពែងចាក់ហើយដុត ក៏មិនដឹងអ្វី ។

ស្តេចសក្កៈស្តាប់ពាក្យរបស់ករិយាហើយ ទើបត្រាស់សួរទាសីថា នែនាង គេជាអ្វីនឹងនាង ? ទាសីឆ្លើយថា បពិត្រលោក គាត់ជាម្ចាស់របស់ខ្ញុំ ។ ស្តេចសក្កៈត្រាស់ថា នាងបែបត្រូវបុរសនេះបៀតបៀន វាយហើយប្រើ ព្រោះហេតុនោះ នាងទើបមិនស្រែកយំ ព្រោះគិតថា បុរសនេះផុតទៅល្អហើយឬ ? ទាសីពោលថា បពិត្រអ្នកជាម្ចាស់ លោកកុំនិយាយយ៉ាងនោះ ពាក្យដែលលោកនិយាយនេះ មិនសមគួរដល់ខ្ញុំទេ អយ្យបុត្តរបស់ខ្ញុំដល់ព្រមដោយខន្តី មេត្តា និងសេចក្តីអនុគ្រោះ ហាក់ដូចជា បុត្រដែលខ្ញុំឲ្យចម្រើនធំធាត់នឹងទ្រូង ។ ស្តេចសក្កៈត្រាស់ថា បើយ៉ាងនោះ ព្រោះហេតុអ្វី ទើបនាងមិនស្រែកយំ ? ចំណែកទាសីនោះ កាលនឹងប្រាប់ហេតុដែលមិនយំ ដល់ស្តេចសក្កៈនោះ ទើបពោល ២ គាថាថា

**យថាបិ ឧទកកុម្ភោ, ភិន្នោ អប្បដិសន្ធិយោ;**
**ឯវំសម្បន្នមេវេតំ, យោ បេតមនុសោចតិ ។**

ក្អមទឹកដែលបែកធ្លាយ តវិញមិនជាប់យ៉ាងណា បុគ្គលសោកស្តាយនឹងអ្នកស្លាប់ទៅកាន់លោកខាងមុខ នេះឯងជាគ្រឿងធៀប ក៏យ៉ាងនោះដែរ ។

**ឧយ្ហមានោ ន ជានាតិ, ញាតីនំ បរិទេវិតំ;**
**តស្មា ឯតំ ន សោចាមិ, គតោ សោ តស្ស យា គតិ ។**

រាងកាយកាលត្រូវគេដុត រមែងមិនដឹងនូវសេចក្ដីខ្សឹកខ្សួល នៃញាតិទាំងឡាយទេ ព្រោះហេតុនោះ ទើបខ្ញុំមិនសោកនឹងម្ចាស់នុំះ គតិណាជារបស់គាត់ គាត់ក៏ទៅកាន់គតិនោះ ។

គាថានោះមានសេចក្ដីអធិប្បាយថា ក្អមទឹកដែលគេលើកឡើង របូតធ្លាក់ បែកជា ៧ ចម្រៀក រមែងមិនអាចនឹងតំភ្ជាប់អំបែងទាំងនោះ ធ្វើឲ្យត្រឡប់ជារបស់ប្រក្រតី បានទៀតយ៉ាងណា សេចក្ដីសោករបស់អ្នកសោកស្ដាយ ចំពោះអ្នកដែលស្លាប់ទៅកាន់លោកខាងមុខហើយនោះ ក៏ឲ្យសម្រេចសេចក្ដីឧបមេយ្យយ៉ាងនោះ ព្រោះមិនអាចធ្វើអ្នកស្លាប់ឲ្យរស់ឡើងវិញ ម្យ៉ាងទៀត អ្នកមានឫទ្ធិសូម្បីអាចតភ្ជាប់ក្អមដែលបែកហើយ ឲ្យពេញដោយទឹកដោយឥទ្ធានុភាព ក៏មិនអាចធ្វើមនុស្សស្លាប់ ឲ្យត្រឡប់ជាប្រក្រតីដូចដើមដោយកម្លាំងឫទ្ធិបានដែរ ។

ស្ដេចសក្កៈស្ដាប់ធម្មកថារបស់អ្នកទាំងអស់ហើយ ទ្រង់មានចិត្តជ្រះថ្លា ត្រាស់ថា អ្នកទាំងឡាយជាមនុស្សមិនប្រមាទ ចម្រើនមរណស្សតិ ចាប់តាំងពីពេលនេះទៅ អ្នកទាំងឡាយកុំធ្វើការងារដោយដៃរបស់ខ្លួនឡើយ យើងជាសក្កទេវរាជ យើងនឹងធ្វើរតនៈទាំង ៧ ប្រការ ដែលប្រមាណមិនបាន ទុកក្នុងផ្ទះរបស់ពួកអ្នក អ្នកទាំងឡាយចូរឲ្យទាន រក្សាសីល ធ្វើឧបោសថកម្ម ចូរជាអ្នកមិនប្រមាទចុះ ។ ត្រាឲ្យឱវាទដល់ជនទាំងនោះហើយ ទ្រង់ធ្វើផ្ទះរបស់ពួកគេឲ្យមានទ្រព្យប្រមាណមិនបាន ហើយស្ដេចជៀសចេញទៅ ។

ព្រះសាស្ដានាំព្រះធម្មទេសនានេះហើយ ទ្រង់ប្រកាសសច្ចៈ និងប្រជុំជាតក ក្នុងវេលាចប់សច្ចៈ កុដុម្ពិកៈតាំងនៅក្នុងសោតាបត្តិផល ។

**តទា ទាសី ខុជ្ជុត្តរា អហោសិ** ទាសីក្នុងកាលនោះ បានមកជានាងខុជ្ជុត្តរា

**ធីតា ឧប្បលវណ្ណា** ធីតាបានមកជានាងឧប្បលវណ្ណា

**បុត្តោ រាហុលោ** *បុត្របានមកជារាហុល*

**មាតា ខេមា** *មាតាបានមកជានាងខេមា*

**ព្រាហ្មណោ បង អហមេវ អហោសឹ** *ចំណែកព្រាហ្មណ៍គឺតថាគតនេះឯង ។*

*ចប់ ឧរគជាតក ។*

*(ជាតកដ្ឋកថា សុត្តន្តបិដក បញ្ចកនិបាត មណិកុណ្ឌលវគ្គ បិដកលេខ ៥៩ ទំព័រ ០៥)*

*ថ្ងៃសុក្រ ៦ កើត ខែស្រាពណ៍ ឆ្នាំច សំរិទ្ធិស័ក ច.ស. ១៣៨០ ម.ស. ១៩៤០*

*ថ្ងៃទី ១៧ ខែ សីហា ព.ស. ២៥៦២ គ.ស.២០១៨*

*ដោយស.ដ.វ.ថ*